ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១១៣/០៩-អេ អេស ឌី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: អន ណេន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: កុយ នាម

ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន អេ អេស ឌី (ខេមបូឌា) ខូអិលធីឌី

អាសយដ្ឋាន : ផ្លូវជាតិលេខ៤ ភូមិកន្ទោកខាងជើង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩២៨ ៩៦៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ពៅ អារុណ ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហព័ន្ធសហជីព_សហជីពឯករាជ្យកម្មករនិយោជិតខ្មែរ
ក្រុមហ៊ុន អេ អេស ឌី

អាសយដ្ឋាន : ផ្លូវជាតិលេខ៤ ភូមិកន្ទោកខាងជើង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១១ ៣៦៩ ៦៤០ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- កញ្ញា រស់ ការ អនុប្រធានសហព័ន្ធសហជីព NIFTUC

| | |
|---|---|
| ២- លោក យុន រ៉េ | មន្ត្រីសហព័ន្ធសហជីព NIFTUC |
| ៣- លោកស្រី សួន សុភាព | ប្រធានសហជីព NIFTUC ក្រុមហ៊ុន អេ អេស ឌី |
| ៤- លោកស្រី សេង ស្រីមុំ | អគ្គលេខាធិការសហជីព NIFTUC ក្រុមហ៊ុន អេ អេស ឌី |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករសុំឱ្យនិយោជកគិតប្រាក់ឈ្នួលជូន ២០០ ភាគរយ ដល់កម្មករ ដែលធ្វើការបន្ថែមម៉ោងថ្ងៃបុណ្យ ០១ ខែឧសភា ឆ្នាំ២០០៩ រីឯកម្មករដែលឈប់សម្រាកថ្ងៃបុណ្យ ០១ ខែឧសភា ឆ្នាំ២០០៩ គិតប្រាក់ឈ្នួលជូនមួយថ្ងៃ ។ និយោជកមិនឯកភាព ។

២- ភាគីកម្មករសុំឱ្យនិយោជកទិញទូរទស្សន៍ និងក្បាលវីស៊ីឌី ដាក់កន្លែងតុបាយមួយគ្រឿង ។ ភាគីនិយោជកពុំអាចទិញជូនបានទេ ពីព្រោះគ្មានលទ្ធភាព ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៣២៤/០៩ ក.ប/កណ. ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ : ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

បញ្ហានៃនីតិវិធី :

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអរលក្ខខណ្ឌការងារឱ្យបានល្អ

ប្រសើរ។ បន្ទាប់មកនាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាលើការទាមទារទាំង០២ចំណុចនោះទេ។ ដូច្នេះ ចំណុចមិនសះជាទាំង០២ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៣២៤/០៩ កប/កណ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំងនេះ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ វេលាម៉ោង ០២:០០ នាទី រសៀល។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់អាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការព្យាយាមផ្សះផ្សាចំណុចមិនសះជាចំនួន០២ចំណុចនេះបន្ថែមទៀត ជាលទ្ធផលភាគីសហជីពដកចំណុចវិវាទទី២ចេញ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយតែទៅលើចំណុចវិវាទទី១ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោម:

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អេ អេស ឌី ជូនលោក ពៅ អារុណ ដើម្បីចូលរួមដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩។

២- វិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន អេ អេស ឌី ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០៣ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អេ អេស ឌី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៨។

៤- លក្ខន្តិកៈក្រុមហ៊ុន ខ្ចុន ខេបបូឌា ខូ អេលធីឌី ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ ២០០៣។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត សហជីពឧស្សាហកម្មកាត់ដេរកម្ពុជា ក្រុមហ៊ុន អេ អេស ឌី លេខ ០១១/០៩ ក.ប/វប ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ។

២- ពាក្យបណ្តឹងរបស់កម្មករបំរើការងារនៅរោងចក្រ អេ អេស ឌី។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេ អេស ឌី លេខ ៣២៤/០៩ ក.ប/

កណ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន អេរអេស ឌី ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៩។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៧៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៧៧ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- នៅក្នុងក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតចំនួនប្រហែល ៧១០ នាក់ ។
- សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា គឺជាដើមបណ្តឹងនៅក្នុងរឿងនេះ ហើយមានភាពជាតំណាង ដែលបានចុះបញ្ជិកានៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩។

ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលជូន២០០ភាគរយដល់កម្មករ ដែលបានធ្វើការបន្ថែមម៉ោងថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ រីឯកម្មករដែលបានឈប់សម្រាកថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ រក្សាប្រាក់ឈ្នួលឱ្យនៅដដែល

- ពេលសវនាការភាគីកម្មករនិយោជិតបានបញ្ជាក់ពីការទាមទារថា ការទាមទារនេះគឺយោងទៅតាមច្បាប់ហើយ ដោយទាមទារសម្រាប់កម្មករ២៤នាក់ដែលបានចូលធ្វើការនៅក្រុមហ៊ុន អេ អេស ឌី នេះនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ តែប៉ុណ្ណោះ។
- នៅមុនចូលឆ្នាំខ្មែរ នាដើមខែមេសា ឆ្នាំ២០០៩ ភាគីកម្មករនិយោជិតនិងនិយោជកបានព្រមព្រៀង ដោយផ្ទាល់មាត់ឱ្យកម្មករទាំងអស់ឈប់សម្រាកនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ (ដែលជាថ្ងៃធ្វើការ) ដើម្បីបន្តការឈប់សម្រាកចូលឆ្នាំខ្មែរមួយថ្ងៃទៀត ប៉ុន្តែត្រូវឱ្យកម្មករនិយោជិតទាំងនោះធ្វើការសងវិញ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ (ជាថ្ងៃឈប់សម្រាកបុណ្យទិវាពលកម្មអន្តរជាតិ) ដោយមិនកាត់ប្រាក់ឈ្នួលសម្រាប់ការឈប់នៅថ្ងៃទី១៧ ខែមេសា ហើយក៏មិនគុណប្រាក់ឈ្នួលជាពីរ តាមច្បាប់ចំពោះការធ្វើការនៅថ្ងៃទី០១ ខែឧសភា នោះដែរ។ ភាគីទាំងពីរអះអាងស្របគ្នាថា កម្មករនិយោជិត ដែលមានការងារ

នៅក្នុងក្រុមហ៊ុនមុនថ្ងៃទី១៧ ខែមេសា បានមកធ្វើការនៅថ្ងៃទី០១ ខែឧសភា ហើយមិនបានទាមទារប្រាក់ឈ្នួលបន្ថែមអ្វីទាំងអស់ ដោយសារពួកគេបានព្រមព្រៀងដោះដូរថ្ងៃឈប់សម្រាកនេះ ។

- ភាគីកម្មករនិយោជិតបានលើកឡើងថា មានកម្មករនិយោជិតចំនួន២៤នាក់ ដែលបានចូលធ្វើការនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ ។ នៅថ្ងៃទី០១ ខែឧសភា នោះ ក្នុងចំនោម២៤នាក់នោះ មាន ៣ នាក់មិនបានមកធ្វើការទេ ហើយ២១នាក់បានមកធ្វើការ ។ និយោជកបានកាត់ប្រាក់ឈ្នួល១ ថ្ងៃសម្រាប់កម្មករ៣នាក់ ដែលមិនមកធ្វើការនៅថ្ងៃទី០១ ខែឧសភា នោះហើយ មិនបានគុណលុយបន្ថែមចំពោះកម្មករ២១នាក់ ដែលបានមកធ្វើការនៅថ្ងៃនោះទេ ។
- ភាគីនិយោជកឯកភាពថា នៅក្នុងចំណោមកម្មករនិយោជិត ដែលចូលធ្វើការនៅក្នុងក្រុមហ៊ុនក្រោយថ្ងៃទី ១៧ ខែមេសា ពិតជាមានការកាត់ប្រាក់ឈ្នួលចំពោះកម្មករនិយោជិតណា ដែលមិនបានមកធ្វើការនៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០០៩ នោះមែន ហើយចំពោះអ្នកដែលមកធ្វើការវិញនិយោជក ក៏មិនបានគុណប្រាក់ឈ្នួលបន្ថែមឡើយ (ដោយអនុវត្តតាមការព្រមព្រៀងជាមួយកម្មករនិយោជិត ដែលមានការងារមុនថ្ងៃទី១៧ ខែមេសា) ហើយការអនុវត្តបែបនេះគឺទូទៅ ដោយមិនសំដៅថា ចូលធ្វើការមុន រឺក្រោយថ្ងៃទី១៧ ខែមេសា នោះទេ ។
- តំណាងនិយោជកដែលចូលរួមក្នុងសវនាការមិនបានចាំចំនួនពិតប្រាកដនោះទេ ។ ចំពោះចំនួនកម្មករនិយោជិត ដែលចូលធ្វើការក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ តែទទួលស្គាល់ថា ពិតជាមានកម្មករមួយចំនួនបានចូលធ្វើការនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ មែន ។
- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ភាគីកម្មករនិយោជិតផ្តល់បញ្ជីឈ្មោះកម្មករ ដែលធ្វើការទាមទារនេះ ។ មានតែកម្មករនិយោជិតចំនួន ០៨នាក់តែប៉ុណ្ណោះ ដែលក្នុងនោះ មានកម្មករ២នាក់ ដែលនិយោជកបានកាត់ប្រាក់ឈ្នួល នៅពេលដែលពួកគាត់មិនបានមកធ្វើការ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ ។ ចំពោះឈ្មោះ យី សុភីន លេខអាយឌី (ID) ៦៤៥៩ បានចូលធ្វើ ការនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ។ ដូច្នេះ មានតែកម្មករចំនួន ០៧ នាក់ ប៉ុណ្ណោះ ពាក់ព័ន្ធការ ទាមទារនេះ ។

| ល.រ | ឈ្មោះ | អត្តលេខ | ថ្ងៃចូលធ្វើការ | ផ្សេងៗ |
|---|---|---|---|---|
| ១ | នៅ សំអាង | ៦៤៩៦ | ២១/០៤/២០០៩ | ក្រុមហ៊ុនកាត់លុយ |
| ២ | ហយ សុភាព | ៦៤៧៥ | ៣០/០៤/២០០៩ | |
| ៣ | ទេស ស្រីមុំ | ៦៤៧៣ | ២៧/០៤/២០០៩ | |
| ៤ | ឆន ឡា | ៦៤៦២ | ២៣/០៤/២០០៩ | ក្រុមហ៊ុនកាត់លុយ |
| ៥ | សុខ សុនេន | ៦៤៧៤ | ២៧/០៤/២០០៩ | |

| | | | | |
|---|---|---|---|---|
| ៦ | តែប សុលេង | ៦៤៧៦ | ២៧/០៤/២០០៩ | |
| ៧ | ស៊ាន ស្រស់ | | ០១/០៥/២០០៩ | |
| ៨ | យី សុភិន | ៦៤៥៩ | ២៨/០៥/២០០៩ | |

## ហេតុផលនៃសេចក្តីសម្រេច

**ចំណុចវិវាទទី១:** កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលជូន២០០ភាគរយដល់កម្មករ ដែលបានធ្វើការបន្ថែមម៉ោងថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ រីឯកម្មករដែលបានឈប់សម្រាកថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ រក្សាប្រាក់ឈ្នួលឱ្យនៅដដែល

នៅក្នុងសំណុំរឿងនេះ តាមរយៈភស្តុតាង ដែលកម្មករនិយោជិតដាក់មកទាក់ទងនឹងឈ្មោះអ្នកទាមទារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមានតែកម្មករនិយោជិតចំនួន៨នាក់ប៉ុណ្ណោះ ប៉ុន្តែមានកម្មករនិយោជិតម្នាក់ឈ្មោះ យី សុភិន លេខអាយឌី(ID) ៦៤៥៩ ដែលបានចូលធ្វើការនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មកររូបនេះបានចូលធ្វើការនៅក្រោយថ្ងៃឈប់សម្រាកបុណ្យ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាតែលើកម្មករចំនួន៧នាក់ប៉ុណ្ណោះ។

កម្មករនិយោជិតបានទាមទារឱ្យនិយោជកសងប្រាក់ឈ្នួលចំនួនមួយថ្ងៃ ដែលនិយោជកបានកាត់ពីកម្មករនិយោជិត ២ នាក់ ដែលបានឈប់សម្រាកនៅថ្ងៃបុណ្យទិវាពលកម្មអន្តរជាតិកាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ និងទាមទារឱ្យនិយោជកផ្តល់បន្ថែមនូវប្រាក់ឈ្នួលចំនួនមួយថ្ងៃក្នុងម្នាក់ដល់កម្មករនិយោជិតចំនួន៥នាក់ ដែលបានស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃទី០១ ខែឧសភា នោះ។ ភាគីកម្មករបានលើកឡើងថា នេះជាការទាមទារស្របតាមច្បាប់តែប៉ុណ្ណោះ។ និយោជកមិនឯកភាពតាមការទាមទារនេះទេ ដោយលើកហេតុផលថា និយោជកអនុវត្តដូចអ្វីដែលនិយោជកធ្វើចំពោះកម្មករនិយោជិតភាគច្រើន ស្របតាមកិច្ចព្រមព្រៀងដោះដូរថ្ងៃឈប់សម្រាក ដែលធ្វើឡើងដើមខែមេសា ឆ្នាំ២០០៩។ ដើម្បីដោះស្រាយចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវពិចារណាថា (ក)-តើការព្រមព្រៀងដោះដូរថ្ងៃឈប់សម្រាក ដែលកម្មករនិយោជិតបានព្រមព្រៀងនោះ គ្របដណ្តប់ដល់កម្មករទាំង៧នាក់ ដែលចូលធ្វើការក្រោយថ្ងៃទី១៧ ខែមេសា នោះដែរ ឬទេ។ (ខ)-តើនិយោជកមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ជូនដល់កម្មករនិយោជិតដែលចូលធ្វើការនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ ដែរ ឬទេ?

(ក)-តើការព្រមព្រៀងដោះដូរថ្ងៃឈប់សម្រាក ដែលកម្មករនិយោជិតបានព្រមព្រៀងនោះ គ្របដណ្តប់ដល់កម្មករនិយោជិតទាំង ៧ នាក់ ដែលចូលធ្វើការក្រោយថ្ងៃទី១៧ ខែមេសា នោះដែរ ឬទេ?

មាត្រា ៦៥ នៃច្បាប់ស្តីពីការងារចែងថា " *កិច្ចសន្យាការងារគឺជាកិច្ចសន្យា ដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានរាជ្ញាគតិ ហើយអាចធ្វើ*

*ធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា* "។

មាត្រា ២២ នៃក្រឹត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាចែងថា "*...កិច្ចសន្យាមានអានុភាពតែទៅលើភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ* "។

យោងតាមបញ្ញត្តិនៃមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែភាគីនៃកិច្ចសន្យាទេ ទើបមានសិទ្ធិរំលាយ ឬបញ្ចប់កិច្ចសន្យាការងារនេះបាន( *សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ ៥៤/០៨-ចុង យ៉ុវ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ៥*) ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការព្រមព្រៀងគ្នាដោយផ្ទាល់មាត់ ដែលបានធ្វើឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ រវាងភាគីកម្មករនិយោជិត និងភាគីនិយោជកពីការធ្វើការដោះដូរថ្ងៃឈប់សម្រាក ដោយកម្មករនិយោជិតឈប់សម្រាកថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ ហើយធ្វើការសងក្រុមហ៊ុនវិញនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ មិនអាចអនុវត្តបានចំពោះកម្មករនិយោជិតចំនួន៧នាក់ ដែលចូលធ្វើការក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ នោះ ពីព្រោះពួកគាត់មិនបានចូលរួមក្នុងការព្រមព្រៀងដោះដូរថ្ងៃឈប់សម្រាកនេះទេ ហើយពួកគេក៏មិនបានឈប់សម្រាកនៅថ្ងៃទី១៧ ខែមេសា នេះដែរ។ ហេតុដូចនេះ ពួកគេមិនមានកាតព្វកិច្ចធ្វើការសងនិយោជកនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ នោះទេ។

(ខ) -តើនិយោជកមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ជូនដល់កម្មករនិយោជិត ដែលចូលធ្វើការនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៩ ដែរឬទេ?

ប្រការ៤ នៃប្រកាសលេខ ១០ របស់ក្រសួងការងារ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចែងថា "*កម្មករនិយោជិត ដែលធ្វើការថ្ងៃឈប់បុណ្យ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់មួយ ដែលស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា...*" ។

មាត្រា ១៦១ នៃច្បាប់ស្តីពីការងារចែងថា "*រៀងរាល់ឆ្នាំក្រសួងទទួលបន្ទុកវិស័យការងារចេញប្រកាសកំណត់ថ្ងៃបុណ្យត្រូវឈប់ដោយមានប្រាក់ឈ្នួលសំរាប់កម្មករនិយោជិតនៃសហគ្រាសទាំងអស់*"។

យោងតាមមាត្រា ១៦១ នៃច្បាប់ការងារ និងប្រកាសលេខ ១០ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើកម្មករនិយោជិតមកធ្វើការនៅថ្ងៃឈប់សម្រាកបុណ្យ គឺកម្មករនិយោជិតមានសិទ្ធិទទួលបាននូវប្រាក់បំណាច់មួយ ដែលស្មើនឹងប្រាក់ឈ្នួលនៃថ្ងៃធ្វើការធម្មតា ពោលគឺបានប្រាក់ឈ្នួលបន្ថែម១ថ្ងៃទៀត ទៅលើប្រាក់ឈ្នួលដែលកម្មករនិយោជិតធ្លាប់ទទួល។

ក្រសួងការងារបានចេញប្រកាសលេខ ២១៤ ករ/ប្រ.ក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការឈប់បុណ្យ ដែលត្រូវបានប្រាក់ឈ្នួលប្រចាំឆ្នាំ២០០៩ ដែលបានដាក់ថ្ងៃទី០១ ខែឧសភា ជាថ្ងៃឈប់សម្រាកបុណ្យ។

ម្យ៉ាងវិញទៀត ច្បាប់ស្តីពីការងារមាត្រា ១៦២ ចែងថា "*....ការឈប់សម្រាកថ្ងៃបុណ្យមិនមែនជាហេតុ*

នាំឱ្យបន្ថយប្រាក់ឈ្នួលប្រចាំខែ ប្រចាំអឌ្ឍមាស ឬប្រចាំសប្តាហ៍ឡើយ"។

យោងតាមមាត្រា ១៦២ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនអាចកាត់ប្រាក់របស់កម្មករនិយោជិតបានទេ នៅពេលដែលកម្មករនិយោជិតឈប់សម្រាកនៅថ្ងៃបុណ្យ ដែលមានប្រាក់ឈ្នួល។

តាមរយៈអង្គហេតុខាងលើ ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតចំនួន២នាក់ ដែលពុំបានមកធ្វើការនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៥ ដែលជាថ្ងៃឈប់សម្រាកបុណ្យ ហើយក៏មិនបានផ្តល់ប្រាក់ឈ្នួលបន្ថែមជូនកម្មករនិយោជិតចំនួន៥នាក់ ដែលពួកគាត់បានមកធ្វើការនៅថ្ងៃនោះដែរ។ ដូចនេះ យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវសងប្រាក់ឈ្នួលមួយថ្ងៃចំពោះកម្មករនិយោជិតចំនួន២នាក់ ដែលនិយោជកបានកាត់ និងត្រូវផ្តល់បន្ថែមនូវប្រាក់ឈ្នួលចំនួនមួយថ្ងៃជូនដល់កម្មករនិយោជិតចំនួន៥នាក់ ដែលបានស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៥នោះ(ឈ្មោះកម្មករនិយោជិត ដែលត្រូវទទួលបានមានដូចខាងក្រោម)។

| ល.រ | ឈ្មោះ | អត្តលេខ | ថ្ងៃចូលធ្វើការ | ផ្សេងៗ |
|---|---|---|---|---|
| ១ | នៅ សំអាង | ៦៤៥៦ | ២១/០៤/២០០៥ | ក្រុមហ៊ុនកាត់លុយ |
| ២ | ហេង សុភាព | ៦៤៧៥ | ៣០/០៤/២០០៥ | |
| ៣ | ទេស ស្រីមុំ | ៦៤៧៣ | ២៧/០៤/២០០៥ | |
| ៤ | ឆន ឡា | ៦៤៦២ | ២៣/០៤/២០០៥ | ក្រុមហ៊ុនកាត់លុយ |
| ៥ | សុខ សុនេន | ៦៤៧៤ | ២៧/០៤/២០០៥ | |
| ៦ | កែប សុហេង | ៦៤៧៦ | ២៧/០៤/២០០៥ | |
| ៧ | ស៊ាន ស្រស់ | | ០១/០៥/២០០៥ | |

យោងតាមអង្គហេតុ ដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

ចំណុចវិវាទទី ១ :

- បង្គាប់ឱ្យនិយោជកត្រូវសងប្រាក់ឈ្នួលមួយថ្ងៃចំពោះកម្មករនិយោជិតចំនួន ២ នាក់ ដែលនិយោជកបានកាត់ និងត្រូវផ្តល់ប្រាក់ឈ្នួលចំនួនមួយថ្ងៃបន្ថែមជូនដល់កម្មករនិយោជិតចំនួន ៥ នាក់ ដែលបានស្ម័គ្រចិត្តមកធ្វើការនៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០០៥ ។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **រ៉ុខ សុឆ្លី**

ហត្ថលេខា: ---------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អ៊ុន ណាន**

ហត្ថលេខា: ---------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **ឡុយ ទាវ**

ហត្ថលេខា: ---------------------------------